ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាងនាមប្រជារាស្ត្រខ្មែរ

សំណុំរឿងព្រហ្មទណ្ឌ
លេខ:៧៣
ចុះថ្ងៃទី១១-០២-២០០៨

សាលដីកា
លេខ: ០៦ "ញ"
ចុះថ្ងៃទី១៨-០២-២០១០

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើ តាមក្រឹត្យលេខ: ០៦ ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណ: នៅសាលាឧទ្ធរណ៍នាដោយមានសមាសភាពដូចតទៅ:

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធាន
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងក្តីព្រហ្មទណ្ឌលេខ:៧៣ ចុះថ្ងៃទី១១-០២-២០០៨ រវាង:

**-ជនជាប់ចោទ:**

១-ឈ្មោះ: [redacted] សារ៉ាក់ ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃនៅ [redacted] មុខរបរធ្វើស្រែ ប្រពន្ធឈ្មោះ: [redacted] មានកូន ០៣នាក់ ឪពុកឈ្មោះ: [redacted] "រ" ម្តាយឈ្មោះ: [redacted] "រ" ទោសពីមុនគ្មាន ឃុំខ្លួន ថ្ងៃទី ២០-១២-២០០៧។

មានលោក [redacted] សុខឃីម ជាមេធាវីការពារក្តីឲ្យឈ្មោះ: [redacted] សារ៉ាក់ ។

២-ឈ្មោះ: [redacted] ទិត ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃនៅផ្ទះ: [redacted]។ (ឃុំខ្លួនថ្ងៃទី០៦-១០-២០០៥)

៣-ឈ្មោះ: [redacted] ផល ភេទប្រុស អាយុ៤៦ឆ្នាំ ជាតិខ្មែរ ។

ជាប់ចោទពីបទ: ប្លន់ម៉ូតូ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៤-៩-២០០៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៦នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២៨៧

-ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ មានទីកន្លែងសព្វថ្ងៃ [redacted] ។

## ង-រឿងហេតុមានដូចតទៅ

នៅថ្ងៃទី២៤-៩-២០០៥ មានជនល្មើសឈ្មោះ [redacted] វិត ហៅ [redacted] ផាន, ឈ្មោះ [redacted] ផល, ឈ្មោះ [redacted] សារ៉ាក់ ហៅ ខ្មៅ និងឈ្មោះ សឿន បានធ្វើសកម្មភាពប្លន់ម៉ូតូជនរងគ្រោះឈ្មោះ [redacted] ស្រួយ នៅចំណុចលូផ្លូវលេខ៣ ភូមិព្រៃគី សង្កាត់ភ្លើងឆេះរទេះ ខណ្ឌដង្កោ រាជធានីភ្នំពេញ។ ជនល្មើសឈ្មោះ [redacted] វិត ត្រូវសមត្ថកិច្ចឃាត់ខ្លួនថ្ងៃទី២៥-៩-២០០៥ ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ:៦២"ឈ" ចុះថ្ងៃទី០៤-៤-២០០៦ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចខាងក្រោម៖

១-ផ្តន្ទាទោស:

ក-ឈ្មោះ [redacted] វិត ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់៦ឆ្នាំ (ប្រាំមួយឆ្នាំ) គិតបន្តចាប់ពីសាលក្រមព្រហ្មទណ្ឌលេខ:២៧"ឋ"ចុះថ្ងៃទី២២-៣-២០០៦ របស់តុលាការក្រុងភ្នំពេញចប់ជាស្ថាពរ ពីបទ: ប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៤-៩-២០០៥ តាមបញ្ញត្តិមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

ខ-ឈ្មោះ [redacted] សារ៉ាក់ ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ

គ-ឈ្មោះ [redacted] ផល ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិខ្មែរ

ម្នាក់ៗដាក់ពន្ធនាគារកំណត់៧ឆ្នាំ(ប្រាំពីរឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនបានតទៅ ពីបទ: ប្លន់ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៤-៩-២០០៥ តាមបញ្ញត្តិមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២-បង្គាប់ឲ្យឈ្មោះ [redacted] វិត, [redacted] សារ៉ាក់, [redacted] ផល រួមគ្នាសងថ្លៃម៉ូតូ, ទូរស័ព្ទ, ជញ្ជៀន សរុបជាប្រាក់ ចំនួន១,២៦៥$(មួយពាន់ពីររយហុកសិបប្រាំដុល្លាអាមេរិក) ទៅឲ្យដើមបណ្តឹងឈ្មោះ [redacted] ចាប់ពីថ្ងៃសាលក្រមស្ថាពរតទៅ បើអ្នកទាំងបីមិនព្រមសងប្រាក់នេះទេ ត្រូវចាប់ដាក់គុកបង្ខំលើរូបកាយតាមច្បាប់ស្តីពីការចាប់ដាក់គុកបង្ខំលើរូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៣-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វិត, កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សារ៉ាក់, [redacted] ផល និងដើមបណ្តឹង បើភាគីណាមិនសុខចិត្តនឹងសាលក្រមនេះ មានសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមច្បាប់ ។

-បានឃើញ របាយការណ៍សំណុំរឿងព្រហ្មទណ្ឌ ចុះថ្ងៃទី០២-៧-២០០៩ របស់សាលាឧទ្ធរណ៍ ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ចុះថ្ងៃទី០៤-១២-២០០៩។

## នាពេលសវនាការ

| | |
|---|---|
| -ជនជាប់ចោទឈ្មោះ [redacted] សារ៉ាក់ | (អវត្តមាន) |
| -មេធាវី [redacted] សុខឃីម | (វត្តមាន) |
| -ជនជាប់ចោទឈ្មោះ [redacted] ខិត | (អវត្តមាន) |
| -ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រួយ | (អវត្តមាន) /៷- |

ទ្បូកឺ

## តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា

តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សារ៉ាក់ បញ្ជាក់ច្បាស់ថា ខ្លួនបានចូលរួមប្លន់ ហើយចម្លើយរបស់ឈ្មោះ [redacted] រ៉ិត ក៏បានឆ្លើយសារភាពអស់ហើយដែរ។ ដូចនេះ សុំលោក ចៅក្រមតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការដដែល ។

-មេធាវី [redacted] **សុខឃីម** បានធ្វើសេចក្តីសន្និដ្ឋានថា: កូនក្តីខ្លួនឈ្មោះ [redacted] សារ៉ាក់ បាន ឆ្លើយបដិសេធរាល់ចម្លើយទាំងអស់ថាអត់បានប្រព្រឹត្តដូចការចោទប្រកាន់ទេ។

ដូច្នេះ នៅពេលនេះ ខ្លួនសំណូមពរសុំសាលាឧទ្ធរណ៍ពិចារណាសម្រេចតាមច្បាប់ ដោយសុំឲ្យកូនក្តីខ្លួនរួចផុតពីបទចោទ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
-ក្រោយពីបានឃើញចម្លើយរបស់ជនជាប់ចោទ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី
-ក្រោយពីបានពិនិត្យគ្រប់ឯកសារដែលពាក់ព័ន្ធ
-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍

## យល់ឃើញថា

១-បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២០-១២-២០០៧ របស់ឈ្មោះ [redacted] សារ៉ាក់ ធ្វើឡើងក្នុង កំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបានយោងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-ជនជាប់ចោទឈ្មោះ [redacted] សារ៉ាក់ បានឆ្លើយបដិសេធថាខ្លួនពុំបានប្លន់ដូចការចោទ ប្រកាន់ឡើយ។ ប៉ុន្តែតាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] រ៉ិត បានបញ្ជាក់ថាក្នុង ការធ្វើសកម្មភាពប្លន់ កាលពីថ្ងៃទី២៤-៩-២០០៥ វេលាម៉ោង៨យប់ ពួកខ្លួនមានគ្នា៤នាក់ គឺ ឈ្មោះ [redacted] ផល, [redacted] សារ៉ាក់, សឿន និងខ្លួន បានធ្វើសកម្មភាពប្លន់យកម៉ូតូ សេ-១០០ ពណ៌ ខ្មៅ របស់ជនរងគ្រោះម៉ែន ។

៣-តាមការយល់ឃើញខាងលើ និងភស្តុតាងក្នុងសំណុំរឿង ឃើញថា មានពិរុទ្ធភាព គ្រប់ គ្រាន់លើជនជាប់ចោទ ពីបទ: ប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៤-៩-២០០៥ តាម មាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៤-រឿងក្តីនេះត្រូវបានសាលាដំបូងក្រុងភ្នំពេញធ្វើការអង្កេត និងលើកយកសំអាងហេតុមក បញ្ជាក់ត្រឹមត្រូវហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនោះ ដូចនេះសាលាឧទ្ធរណ៍មិន លើកយកសំអាងហេតុដដែលនោះមកបញ្ជាក់ជាថ្មីទៀតទេ ។

៥-សាលក្រមព្រហ្មទណ្ឌលេខ:៦២"ឃ" ចុះថ្ងៃទី០៤-៤-២០០៦ របស់សាលាដំបូងក្រុង ភ្នំពេញសម្រេចមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយគប្បីតម្កល់ទុកជាបានការពេញទាំងមូល។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២០-១២-២០០៧ របស់ឈ្មោះ [redacted] សារ៉ាក់ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ៦២"ឃ" ចុះថ្ងៃទី០៤-៤-២០០៦ របស់សាលាដំបូងក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៣-បន្តការឃុំខ្លួនលើជនជាប់ចោទឈ្មោះ [redacted] សារ៉ាក់ ។

៤-សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី១៨-០២-២០១០ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ចំពោះមុខមេធាវីជនជាប់ចោទ ទុកសិទ្ធិឲ្យប្តឹងតវ៉ាតាមកំណត់ច្បាប់ ។/.

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និង កងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- |
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted], [redacted] | ហត្ថលេខា [redacted] |

---

ត្រូវតាមច្បាប់ដើម-

ភ្នំពេញ, ថ្ងៃ ... ឆ្នាំ២០១៥

ក្រឡាបញ្ជី

[redacted]

ក្រឡាបញ្ជីសាលាឧទ្ធរណ៍

[redacted]